ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**************

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៤ / ២៨.០១.២០១០
សាលដីកា
លេខៈ ៧៨ ក្រ.III.ស/២៦.១០.២០១២

# នាមនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅៈ

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted]ាន់ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរៈកម្មករ កើតនៅ ភូមិតាប៉ាង ឃុំអំពិល ស្រុកបាគង ខេត្តសៀមរាប លំនៅមុនចាប់ខ្លួន [redacted] ស្រុកបវេល ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន២នាក់ ទោសពីមុនគ្មាន។

មានមេធាវីការពារ លោកស្រី [redacted] ម៉េងអ៊ាម ។

<u>ត្រូវចោទពីបទៈ</u> ប្លន់ ប្រព្រឹត្តនៅភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ែម ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ក្រុមទី៤ ភូមិគ្រួស ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

**<u>ឯដំណើររឿងមានដូចតទៅៈ</u>**

តាមពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] យ៉ែម បញ្ជាក់ថា កាលពីថ្ងៃទី២៣ ៖

ខែឧសភា ឆ្នាំ២០០៥ វេលាម៉ោង១ និង៤៥នាទី ខ្លួនបានជិះម៉ូតូពីក្រោយចៅខ្លួន មកពីស្រែ លុះមកដល់ត្រង់ចំណុចខាងកើត ភូមិតាម៉ៅ ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង, ពេលនោះពួកចោរបានជិះម៉ូតូពីទិសខាងកើត មកបុកម៉ូតូខ្លួនដែលជិះមកពីទិសខាងលិច បណ្តាលឲ្យដួល ហើយពួកចោរបានលើកម៉ូតូខ្លួន ហើយដកកាំភ្លើងខ្លីមកសំឡុតខ្លួនថា លែងដៃពីម៉ូតូប្រយត្ន័អញបាញ់បែកក្បាល វានិយាយរួចក៏ឡើងជិះម៉ូតូខ្លួនទៅទិសខាងលិចបាត់ទៅ។ ពេលនោះ ខ្លួនក៏បានមកប្តឹងសមត្ថកិច្ចតែម្តងទៅ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១២៧ «ង» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១. ឲ្យឈ្មោះ[redacted]វ៉ាន់ភេទប្រុស អាយុ៣៨ឆ្នាំ រួចផុតពីបទចោទប្រកាន់។

ពីបទ ប្លន់ ប្រព្រឹត្តនៅភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ ប្តឹងផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៦៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ១២៧«ង» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា សង្ខេបអង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ប៉ូ យ៉ែម បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង

ជនជាប់ចោទឈ្មោះ [redacted]វ៉ាន់ ឆ្លើយថាៈ ខ្លួនពុំបានធ្វើសកម្មភាពប្លន់ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ នៅភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង ហើយខ្លួនក៏មិនដែលស្គាល់ពួកក្រុមជនល្មើសទាំងនោះដែរ។ ខ្លួនត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ ពីបទ ប្លន់សម្លាប់នៅភូមិគ្រួស, កាលប្លន់នៅភូមិគ្រួសនោះ ឈ្មោះ [redacted]ឆាយ ជាអ្នកបបួលខ្លួនទៅរកស៊ីប្លន់ ហើយខ្លួនពិតជាបានចូលរួមមែន នៅពេលនោះ។ សំណូមពរ សុំលើកលែងចោទប្រកាន់ខ្លួន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ពាក់ពន្ធ័សំណុំរឿងនេះ ក្រោយពីការសួរដេញដោល ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ តំណាង ៖

មហាអយ្យការយល់ឃើញថា មានចំណុចច្រើនមិនស៊ីសង្វាក់គ្នា ទី១ ទីកន្លែងកើតហេតុ ជនជាប់ចោទគាត់សារភាពថា គាត់បានចូលរួមប្លន់មែន មានគ្នាបីនាក់ដោយមានការណែនាំពីឈ្មោ[redacted]ាយ ពេលនោះជនជាប់ចោទថា ពេលប្លន់មិនបានសម្រេចទេគឺប្លន់មនុស្សប្រុសតែម្នាក់ទេ, រីឯអង្គហេតុនេះជនរងគ្រោះមាន គ្នាពីរនាក់ ជីដូន និងចៅ។ រឿង១ទៀត ជនជាប់ចោទគាត់មានសំណុំរឿងមួយទៀត ដែលត្រូវតុលាការចាប់ខ្លួន ពីបទប្លន់សំលាប់ ហើយគាត់ក៏បានអះអាងថា គាត់អត់បានប្រព្រឹត្តដែរ។ ចំពោះអង្គហេតុនៅពេលនេះ ជនជាប់ចោទឆ្លើយថា ខ្លួនអត់បានប្រព្រឹត្តទេ តែខ្លួនបានបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀត។ តំណាងមហាអយ្យការសុំឲ្យសភាព្រហ្មទណ្ឌពិចារណា ទាក់ទងទៅនឹងចម្លើយទាំងឡាយដែលមាននៅក្នុងសំណុំរឿង ទាក់ទងនឹងចម្លើយសាក្សីក៏គ្មាន ឯជនរងគ្រោះបានឆ្លើយថាគាត់មិនចាំទេ, សូមក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ បើតាមចម្លើយជនជាប់ចោទអះអាងថា ជនជាប់ចោទមានគ្នាបីនាក់ មានឈ្មោះ [redacted]ាយ ជាមេក្លោង ពេលធ្វើសកម្មភាពពេលនោះ គឺគាត់បានរត់ដោយមានការភ័យខ្លាច ជនរងគ្រោះមានតែប្រុសម្នាក់ទេ, តែរឿងដែលមានអង្គហេតុនៅថ្ងៃនេះ ជនជាប់ចោទឆ្លើយថា គាត់មិនបានប្រព្រឹត្តទេ សូមក្រុមប្រឹក្សាពិចារណាអង្គហេតុនេះមានជនរងគ្រោះពីរនាក់ គឺជីដូន និងចៅកូនក្តីខ្លួនបានបដិសេធថាគាត់មិនបានចូលរួមប្រព្រឹត្តទេ, ឯអង្គហេតុមួយទៀតគឺមានជនរងគ្រោះប្រុសតែម្នាក់ប៉ុណ្ណោះហើយអង្គហេតុនេះកូនក្តីខ្លួនក៏បានសារភាពរួចហើយៗ តុលាការបានសម្រេចផ្តន្ទាទោសរួចហើយៗ គាត់មិនបានប្តឹងឧទ្ធរណ៍ទេ។ ឯសាក្សីក៏បានឆ្លើយថាមិនមែនកូនក្តីខ្លួនដែរ, សាលក្រមរបស់សាលាដំបូងសម្រេចមានលក្ខណៈត្រឹមត្រូវ ចំពោះបណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការមានលក្ខណៈអូសបន្លាយ សូមលោកប្រធានពិនិត្យ និងពិចារណា សំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់តាមច្បាប់រួច

## សំអាងហេតុ

១. បណ្តឹងឧទ្ធរណ៍លេខ ១៦៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,

២. តាមចម្លើយជនជាប់ចោទថា ខ្លួនពុំបានធ្វើសកម្មភាពប្លន់ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ នៅភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង ហើយខ្លួនក៏មិនដែលស្គាល់ពួកក្រុមជនល្មើសទាំងនោះដែរ។ ខ្លួនត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៧ ពីបទ ប្លន់សម្លាប់ នៅភូមិគ្រួស, ឃុំ

កាលប្លន់នៅភូមិគ្រួសនោះ ឈ្មោះ [redacted] ឆាយ ជាអ្នកបបួលខ្លួនទៅរកស៊ីប្លន់ ហើយខ្លួនពិតជាបានចូលរួមមែន នៅពេលនោះ។

៣. តាមចម្លើយឈ្មោះ [redacted] អ៊ិត ជាជនរងគ្រោះដែរថា មនុស្សបីនាក់ ដែលកាក់ម៉ូតូខ្លួននោះ ពុំមែន ជាឈ្មោះ [redacted]ាន់ នោះទេ។

៤. គ្មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅ ភូមិអូរតាគី ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋឡើយ។ គួរឲ្យរួចខ្លួនពីបទចោទនេះ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ១២៧ «ង» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលាដំបូង ខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាមអង្គហេតុ និងច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៦៨ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹង គតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៧ «ង» ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ របស់សាលា ដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១២ និងប្រកាសជា សាធារណៈ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៗ**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

................................................................................................

| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី 04 ខែ 6 ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |